# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ....០៣...............អ.ន.ក

ថ្ងៃ..សុក្រ.....ខែ..បុស្ស..ឆ្នាំ..រកា...នព្វស័ក..ព.ស.២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី..១២...ខែ..មករា...ឆ្នាំ ២០១៨....

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** : របាយការណ៍ប្រចាំឆ្នាំ ស្តីពីលទ្ធផលបញ្ចប់ការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៧ ការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៧ និងល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ “ គិតត្រឹមថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ ” ។

**ជូនភ្ជាប់** : របាយការណ៍លំអិតប្រចាំឆ្នាំ ស្តីពីលទ្ធផលបញ្ចប់ការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៧ ការងារប្រមូលផលស្រូវរដូវវស្សា ឆ្នាំ២០១៧ និងល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ “ គិតត្រឹមថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ ” ចំនួន០១ច្បាប់ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៧ ការងារប្រមូលផលស្រូវរដូវវស្សា ឆ្នាំ២០១៧ និងល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ សម្រេចបាន:

**១.លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលកសិកម្មរដូវវស្សា ២០១៧ :**

| | | | | |
|---|---|---|---|---|
| **ក. ដំណាំស្រូវ** | : ស្ទូង និងព្រោះ អនុវត្តបានចំនួន ២.៦៥៧.៧៦៨ ហ.ត ស្មើនឹង ១០៦,៤៥ % នៃផែនការចំនួន | ២.៤៩៦.៧៩០ ហ.ត | ច្រើនជាងឆ្នាំមុន | ៥៨.១៨២ ហ.ត |
| **ខ. ដំណាំរួមផ្សំ** | : អនុវត្តបាន | ៨៣៤.៧១៤ ហ.ត | តិចជាងឆ្នាំមុន | ២.៣៤០ ហ.ត |
| **គ. ដំណាំឧស្សាហកម្ម** | : អនុវត្តបាន | ៩៨.៣៤៣ ហ.ត | ច្រើនជាងឆ្នាំមុន | ៥.៣៨៣ ហ.ត |

**២. ការងារប្រមូលផលស្រូវរដូវវស្សា ឆ្នាំ២០១៧ :**

មកដល់ពេលនេះ កសិករបានប្រមូលផលស្រូវរដូវវស្សាលើផ្ទៃដី ២.៣៨០.៨៦៧ ហ.ត ទទួលបានទិន្នផលមធ្យម ៣,០៣៧ តោន/ហ.ត និងបរិមាណផលសរុប ៧.២៣១.៤២៨ តោន។

**៣. ការងារបង្កបង្កើនផលកសិកម្មរដូវប្រាំង ឆ្នាំ២០១៧-២០១៨ :**

| | | | | |
|---|---|---|---|---|
| **ក. ដំណាំស្រូវ** | : ស្ទូង និងព្រោះអនុវត្តបានចំនួន ៣១៧.៥៩៦ ហ.ត ស្មើនឹង ៧១.៥៨ % នៃផែនការចំនួន | ៤៤៣.៧០០ ហ.ត | លឿនជាងឆ្នាំមុន | ៨.០៩២ ហ.ត |
| **ខ. ដំណាំរួមផ្សំ** | : អនុវត្តបាន | ៣៩.៦១២ ហ.ត | យឺតជាងឆ្នាំមុន | ២.០៦០ ហ.ត |
| **គ. ដំណាំឧស្សាហកម្ម** | : អនុវត្តបាន | ៨.៦៧៩ ហ.ត | លឿនជាងឆ្នាំមុន | ២.៥៧៦ ហ.ត |

អាស្រ័យហេតុដូចបានគោរពជូនខាងលើសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ហ៊ាន វណ្ណហាន**

**ចំលងជូន ៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តមអគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីគោរពជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានផែនការ និងស្ថិតិ
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (០២៣) ៨៨៣ ៤២៧. ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh, Cambodia, Phone: (023) 883 427, Fax: (023) 883 427